ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

ទីស្តីការ
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
Ministry of Posts and Telecommunications
លេខ : ១៤៤ បទ.ប្រក

រាជធានី ភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០១

# ប្រកាស

## ស្តីអំពីការរៀបចំ និងការគ្រប់គ្រង
## ប្រព័ន្ធ និងសេវាកម្ម អ៊ិនធឺណែត (Internet) និងប្រភេទសេវា VoIP
## នៅព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញ ព្រះរាជក្រឹត្យលេខ នស រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីអំពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញ ព្រះរាជក្រម លេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីអំពីប្រកាសឱ្យប្រើច្បាប់ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញ ព្រះរាជក្រម លេខនស /រកម /០១៩៦ /២០ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីការបង្កើត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- បានឃើញ អនុក្រឹត្យលេខ ៦៦ / អនក្រ-បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- បានឃើញ អនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ១៩៨៧ ស្តីអំពីប្រៃសណីយ៍ និងទូរគមនាគមន៍ ។
-យោងតាមសេចក្តីសំរេចអង្គប្រជុំថ្នាក់ដឹកនាំ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ថ្ងៃទី ១៥មិថុនា ឆ្នាំ ២០០១ ។

## សំរេច

ប្រការ ១ : ការរៀបចំប្រព័ន្ធអ៊ិនធឺណែតណូដ (Internet Node) ឬប្រព័ន្ធដែលប្រើ Internet Protocol ( IP Based Network ) និងការបន្តភ្ជាប់រវាងប្រព័ន្ធទាំងនោះ ត្រូវមានច្បាប់អនុញ្ញាតិពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ : 855 - 23.426993 / 426510
ទូរសារ : 855 - 23.426992 / 426011
Corner street 13 and 102 Wat Phnom
Section - Daun Penh District P.Penh
Tel : 855 - 23.426993 / 426510
Fax : 855 - 23.426992 / 426011

១.១/ អ៊ិនធឺណែតណូដ (Internet Node) ដែលមានមូលដ្ឋានបច្ចេកទេសក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវបានកំណត់នូវ IP Address របស់ប្រទេសកម្ពុជា ។

១.២/ អ៊ិនធឺណែតណូដ (Internet Node) ត្រូវបន្តភ្ជាប់គ្នា ( Peering ) ពីមួយទៅមួយតាមលក្ខណៈបច្ចេកទេសដែលកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

១.៣/ ក្រសួងប្រៃសណីយ និងទូរគមនាគមន៍ មានភារៈកិច្ច តម្លើង និងគ្រប់គ្រងបច្ចេកវិទ្យាភ្ជាប់ទូរស័ព្ទតាម អ៊ិនធឺណែត (VoIP) ។

ប្រការ ២ : ការធ្វើសេវាកម្ម និងការប្រើប្រាស់ទូរស័ព្ទតាមប្រព័ន្ធ អ៊ិនធឺណែត (VoIP) សំរាប់ភ្ជាប់សន្ទនាក្នុងប្រទេស និងអន្តរជាតិអាចប្រព្រឹត្តទៅបាន ស្របតាមប្រការ ១ចំណុច ១.៣ ខាងលើ ។

ប្រការ ៣ : ត្រូវហាមឃាត់ជាដាច់ខាតនូវ :

៣.១/ ការនាំចូលនិងប្រើប្រាស់រាល់បរិក្ខាបច្ចេកទេសទាំងឡាយសំរាប់ធ្វើសេវាកម្ម ទូរស័ព្ទ (VoIP) ទៅអន្តរជាតិដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ និងទូរគមនាគមន៍ ។

៣.២/ ការផ្គត់ផ្គង់ ឬការប្រើប្រាស់ប័ណ្ណអ៊ិនធឺណែត (IP Cards) និងបណ្ណស័ព្ទទាំងឡាយ ( Phone Cards ) ដែលផលិត ឬនាំចូលដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយនិងទូរគមនាគមន៍

ប្រការ ៤ : ប្រតិបត្តិករដែលបានទទួលអាជ្ញាប័ណ្ណផ្តល់សេវាកម្មអ៊ិនធឺណែត (ISP) ឬជនណាដែលមិនគោរពតាមបទបញ្ញត្តិនៃប្រកាសនេះ ត្រូវបញ្ឈប់សកម្មភាពជាបន្ទាន់ ។
បើសិនសកម្មភាពនោះនៅតែបន្ត ប្រតិបត្តិករ ឬជននោះត្រូវផ្តន្ទាទោសតាមច្បាប់ ។

ប្រការ ៥ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : ខុទ្ទកាល័យ អធិការដ្ឋាន និងគ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មានភារៈកិច្ចអនុវត្តន៍តាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ៧ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា ។

រ ដ្ឋ ម ន្ត្រី

សូ-ខុន

កន្លែងទទួល:

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- រាជកិច្ច

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៦ "ដើម្បីអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ.